# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជាផ្សាយផ្ទាល់នៅព្រះសហគមន៍សន្តសិលានិងសន្តប៉ូល
# ភ្នំពេញថ្មី ថ្ងៃទី២២ ខែមីនា ឆ្នាំ២០២០
## ជំនឿរបស់យើងជាសេចក្តីសង្ឃឹមដែលនាំឲ្យយើងតស៊ូ

**អត្ថបទទី១៖ សាមូអែលទី១ ១៦,១ខ.៦-៧.១០-១៣ខ**

ព្រះអម្ចាស់មិនវិនិច្ឆ័យដូចមនុស្សលោក ដែលមើលតែសំបកក្រៅប៉ុណ្ណោះទេ ព្រះអម្ចាស់ទត មើលចិត្តគំនិតវិញ។ ១សម ១៦,៧ខ

**អត្ថបទទី២៖ អេភេសូ ៥,៨-១៤**

ផលនៃពន្លឺនោះ គឺសេចក្តីសប្បុរស សេចក្តីសុចរិត និងសេចក្តីពិតគ្រប់បែបយ៉ាង។ អភ ៥,៩

**ដំណឹងល្អ៖ យ៉ូហាន ៩,១-៤១**

ព្រះយេស៊ូមានព្រះបន្ទូលតបថា៖ «គាត់ខ្វាក់ មិនមែនមកពីបាបរបស់ឪពុកម្តាយគាត់ ឬបាបរបស់គាត់ទេ គាត់ខ្វាក់ដូច្នេះ ដើម្បីឲ្យព្រះជាម្ចាស់បង្ហាញកិច្ចការរបស់ព្រះអង្គនៅក្នុងគាត់។ យហ ៩,៣

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ ជាអាទិត្យទីបួននៃរដូង៤០ថ្ងៃជាអាទិត្យនៃអំណរ ជាពេលវេលាដែលយើងត្រូវតែមានអំណរសប្បាយនៅកណ្តាលនៃរដូវ៤០ថ្ងៃ ដែលត្រៀមខ្លួនដើម្បីរងទុក្ខលំបាកជាមួយព្រះយេស៊ូ និងរួមដំណើរជាមួយព្រះយេស៊ូដែលមានព្រះជន្មរស់ឡើងវិញ។ ប៉ុន្តែអំណរសប្បាយនេះដូចជារងទុក្ខលំបាកមុនពេលវេលា នៅពេលយើងមើលស្ថានភាពនៃពិភពលោកទាំងមូល។ ពេលនេះទូទាំងពិភពលោក មាន១០០០លាននាក់ដែលត្រូវតែស្ថិតនៅក្នុងផ្ទះផ្ទាល់ខ្លួន គ្មានសិទ្ធិធ្វើដំណើរទៅណា ដោយសារកូវីដ១៩បានសម្លាប់មនុស្សយ៉ាងច្រើន។ មិនតែប៉ុណ្ណោះ វាបានសម្លាប់តាមផ្លូវសេដ្ឋកិច្ចដែរ តាមផ្លូវទំនាក់ទំនងនៅក្នុងសង្គម និងសម្លាប់ចិត្តគំនិតរបស់មនុស្សមួយចំនួនដែលកំពុងភ័យខ្លាច។ ប្រសិនបើ យើងមើលស្ថានភាពកូវីដនៅប្រទេសកម្ពុជាមិនទាន់មានអ្នកស្លាប់នៅឡើយទេ ប៉ុន្តែឥទ្ធិពលនៃជំងឺនេះធ្វើឲ្យបិទសាលា គ្រប់សាសនាមិនអាចជួបជុំគ្នា ព្រំដែនចាប់ផ្តើមបិទទ្វារ ភោជនីយដ្ឋានមួយចំនួនបិទទ្វារ ជើងហោះហើរត្រូវបានលុបចោល កម្មករកម្មការិនីរោងចក្រមួយចំនួនអស់ការងារធ្វើ។ នៅគ្រប់ទីកន្លែងយើងត្រូវពាក់ម៉ាស់ និងលាងដៃជាមួយអាកុល ឬដែលសម្លាប់មេរោគ ប្រជាជនរង់ចាំព័ត៌មានថ្មីៗពីក្រសួងសុខាភិបាល។ យប់មិញ នៅប្រទេសកម្ពុជាយើងមានអ្នកឆ្លងជំងឺកូវីឌ១៩នេះមាន៥៣នាក់ក្នុង១៤ខេត្ត។

ពិតមែន ការភ័យខ្លាចបានចូលនៅក្នុងជីវិតរបស់យើងផ្ទាល់ ណែនាំឲ្យយើងភ័យខ្លាចជួបជាមួយបងប្អូនឯទៀតៗ។ យើងឃើញស្ថានភាពសេដ្ឋកិច្ចនៃគ្រួសារមួយចំនួនបានធ្លាក់ចុះ

ដោយសារគ្មានប្រាក់ខែ គ្មានការងារធ្វើ គ្មានចំណូល សិស្សានុសិស្សមួយចំនួនកំពុងពិបាក ដោយសារសាលាត្រូវបិទទ្វារមុនកំណត់។ ព្រឹកនេះ ខ្ញុំថ្វាយអភិបូជានៅក្នុងព្រះវិហារសន្តសិលា និងសន្តប៉ូលភ្នំពេញថ្មី ជាមួយលោកឪពុកលី ជាមួយលោកឪពុកដូស្ស និងជាមួយនិស្សិតទេវវិទ្យាល័យ ដែលយើងជាក្រុមគ្រួសារមួយយ៉ាងតូចដើម្បីចូលនៅក្នុងអភិបូជា និងការអធិដ្ឋានជាមួយបងប្អូនទាំងអស់ដែលនៅតាមផ្ទះនិងកន្លែងផ្ទាល់ខ្លួន។ យើងរួមគ្នា យើងអាចឲ្យព្រះជាម្ចាស់លើកទឹកចិត្តយើង ឲ្យព្រះអង្គឆ្លើយតបនឹងសំណួររបស់យើង ឲ្យព្រះអង្គចូលនៅក្នុងទុក្ខលំបាករបស់យើង។ ជូនកាល គ្រួសារមួយចំនួនមានទុក្ខលំបាកពីយូរមកហើយ នៅពេលនេះធ្វើឲ្យមានទុក្ខលំបាកកាន់តែខ្លាំងថែមទៀត។

អត្ថបទគម្ពីរដែលយើងបានស្តាប់ បានបង្ហាញអំពីសេចក្តីស្រឡាញ់របស់ព្រះយេស៊ូចំពោះអ្នកខ្វាក់ភ្នែកពីកំណើត។ តាមពិត ទាំងគ្រួសារគាត់ ទាំងធម្មាចារ្យ ទាំងប្រជាជន កំពុងមើលឃើញអ្នកដែលខ្វាក់ពីកំណើតដូចជាគាត់ពោរពេញដោយអំពើបាប។ ប៉ុន្តែ ព្រះយេស៊ូមិនចង់ឲ្យយើងចូលនៅក្នុងគំនិតនេះទេ ព្រះយេស៊ូចង់បំផ្លាញគំនិតដែលវិនិច្ឆ័យកាត់ក្តីបងប្អូនឯទៀតៗ ព្រះយេស៊ូបានឆ្លើយយ៉ាងច្បាស់ថា "**ទាំងគាត់ ទាំងឪពុកម្តាយគាត់មិនមែនជាមនុស្សមានបាបទេ នេះជាពេលវេលាដើម្បីឲ្យយើងធ្វើកិច្ចការរបស់ព្រះជាម្ចាស់ ដែលបានណែនាំឲ្យខ្ញុំយាងមកនៅក្នុងពិភពលោកនេះ ដើម្បីណែនាំឲ្យពិភពលោកចេញពីភាពងងឹត និងរកឃើញពន្លឺដ៏ពិតប្រាកដ**"។ ព្រះយេស៊ូ បានណែនាំឲ្យមនុស្សខ្វាក់ភ្នែកពីកំណើតនេះបានមើលឃើញនៅថ្ងៃសប្ប័ទ ដើម្បីឲ្យគាត់មើលឃើញទាំងជីវិតទាំងដួងចិត្តរបស់គាត់។ នៅពេលគាត់មើលឃើញហើយ ប្រជាជនបានរើសអើងគាត់និងបណ្តេញគាត់ថែមទៀត ប៉ុន្តែព្រះយេស៊ូបានគង់នៅដើម្បីទទួលស្វាគមន៍គាត់ ណែនាំឲ្យគាត់ចូលយ៉ាងជ្រៅនៅក្នុងដួងចិត្តរបស់គាត់។ គាត់អាចប្រកាសជំនឿរបស់គាត់ថា ពិតមែនខ្ញុំជឿសង្ឃឹមលើព្រះយេស៊ូដែលជាព្រះគ្រីស្ត ដែលជាព្រះសង្គ្រោះ។

បងប្អូនជាទីស្រឡាញ់!

ស្ថានភាពដែលយើងមាននៅក្នុងឆ្នាំ២០២០នេះ យើងមិនដែលមើលឃើញនៅក្នុងពិភពលោករបស់យើង ដែលមានការអភិវឌ្ឍន៍យ៉ាងខ្លាំង ដែលមានឯកទេសជាន់ខ្ពស់ ដែលមានអ្វីៗអស់ហើយ នៅពេលនេះដូចជាចូលនៅក្នុងព្រំដែនផ្ទាល់ខ្លួន ដោយរកមិនឃើញអំណាច សមត្ថភាព ដើម្បីប្រឆាំងនឹងមេរោគកូរ៉ូណានេះ។ តាមពិត មានតែព្រះជាម្ចាស់ដែលមានឫទ្ធានុភាពសព្វប្រការ ព្រះជាម្ចាស់មិនមានឯកទេសជាន់ខ្ពស់ ព្រះជាម្ចាស់មិនមានសមត្ថភាពប្លែកៗទេ ព្រះជាម្ចាស់មិនមានលុយឬទ្រព្យសម្បត្តិទេ ប៉ុន្តែតាមរយៈព្រះយេស៊ូដោយប្រើភក់យ៉ាងតិចយកទៅបិទ

លើភ្នែកមនុស្សខ្វាក់ បានណែនាំឲ្យគាត់មើលឃើញ។ ព្រះជាម្ចាស់ មានឫទ្ធានុភាពតែមួយដែលអាចឈ្នះអ្វីៗទាំងអស់ គឺសេចក្ដីស្រឡាញ់ដែលគ្មានព្រំដែន។

សម្រាប់បងប្អូនដែលបានទទួលពិធីគ្រាស់ហៅយ៉ាងឱឡារិក (ជំហានទី២) ព្រឹកនេះតាមពិតជាពេលវេលាដែលត្រូវធ្វើពិធីជំរះចិត្តគំនិតទីពីរ ជាពេលវេលាទូលអង្វរព្រះយេស៊ូដើម្បីបំផ្លាញសេចក្ដីអាក្រក់ បំផ្លាញមារកំណាចនៅក្នុងជីវិតរបស់យើង ដើម្បីណែនាំឲ្យយើងមើលឃើញសាជាថ្មី។ ពេលយើងមើលបងប្អូនដែលនឹងទទួលអគ្គសញ្ញាជ្រមុជទឹកនៅខាងមុខនេះ យើងមើលឃើញរបៀបដែលបងប្អូនបានកែប្រែនៅក្នុងជីវិតផ្ទាល់ខ្លួន ពេលបានជួបជាមួយព្រះយេស៊ូផ្ទាល់ ដោយសារគ្រីស្តបរិស័ទមួយចំនួនបានផ្ដល់សក្ខីភាព យើងបានចាប់ផ្ដើមដើរបន្តិចម្ដងៗតាមព្រះយេស៊ូ។ ព្រះយេស៊ូ បានចាប់ផ្ដើមបើកភ្នែកបងប្អូនបន្តិចម្ដងៗដោយបង្រៀនអំពីរបៀបស្រឡាញ់ថ្មី ដោយបង្រៀនអំពីតម្លៃនៃជីវិតសាជាថ្មី ដោយប្រទានវិញ្ញាណថ្មីដើម្បីស្រឡាញ់បងប្អូនឯទៀតៗនៅក្នុងរបៀបថ្មី។ យើងដឹងថា ព្រះយេស៊ូមិនវិនិច្ឆ័យកាត់ក្ដីយើងនៅលើសភាពខាងក្រៅ ប៉ុន្តែព្រះអង្គមើលឃើញអ្វីដែលយើងមាននៅក្នុងដួងចិត្តរបស់យើង ដើម្បីប្រទានជីវិតថ្មី។

រដូវ៤០ថ្ងៃឆ្នាំនេះជារដូវមួយប្លែក យើងទាំងអស់គ្នាត្រូវតែទូលអង្វរឲ្យព្រះជាម្ចាស់យាងចូលនៅក្នុងដួងចិត្តរបស់យើង ដើម្បីឲ្យព្រះអង្គដាក់ភក់លើភ្នែករបស់យើង។ ភក់នេះ ជាដីស្អុយពិតមែន ប៉ុន្តែនៅក្នុងសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ ភក់នេះបានណែនាំឲ្យភ្នែក ឲ្យជីវិត ឲ្យអំពើបាប ឲ្យភាពងងឹតរបស់យើងងាប់ទាំងអស់ ដើម្បីឲ្យយើងរកឃើញពន្លឺ។ ពេលយើងមើលពិភពលោកពេលនេះ យើងមានអារម្មណ៍ថាដូចជាមានអ្វីមកគ្របបាំងពិភពលោកយើង ដែលណែនាំឲ្យយើងដូចជារស់នៅក្នុងកាលៈទេសៈអវសានកាលនៃពិភពលោក។ ប៉ុន្តែ ដោយសារការអធិដ្ឋានរបស់យើង ដោយសារការតមអាហាររបស់យើង ដោយសារសេចក្ដីស្រឡាញ់ដែលយើងបន្តចែករំលែកនៅក្នុងរបៀបថ្មី យើងដឹងថាយើងអាចធ្វើដំណើរទៅដល់ថ្ងៃដែលព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ។ ឆ្នាំនេះ យើងមិនអាចថ្វាយអភិបូជានៅរាត្រីបុណ្យចម្លងជាផ្លូវការ ប៉ុន្តែយើងដឹងថានៅលើឈើឆ្កាងសេចក្ដីស្រឡាញ់បានផុសឡើង សេចក្ដីសង្ឃឹមបានផុសឡើង ពន្លឺរបស់ព្រះគ្រីស្តត្រូវតែយាងមកសាជាថ្មីដើម្បីបំភ្លឺភាពងងឹតដែលមាននៅលើផែនដីនេះ។ នៅថ្ងៃដែលព្រះនាងម៉ារីទទួលដំណឹងល្អពីទេវទូតកាព្រីអែលខាងមុខនេះ ជាពេលវេលាដើម្បីទូលអង្វរព្រះនាងម៉ារី សូមឲ្យព្រះនាងម៉ារីថែរក្សាពិភពលោក ថែរក្សាប្រទេសកម្ពុជាយើង។ នៅថ្ងៃនោះ សូមបងប្អូនអុជទៀនតូចមួយនៅតាមផ្ទះ ដែលជាសញ្ញាសម្គាល់ថាព្រះយេស៊ូយាងមកដើម្បីបំភ្លឺ

ពិភពលោក ដោយជឿថាព្រះជាម្ចាស់បានចាត់ព្រះបុត្រា មកចាប់កំណើតនៅក្នុងផ្ទៃព្រះនាងម៉ារី ដើម្បីឲ្យយើងទទួលជីវិតសាជាថ្មី។

សូមបងប្អូនបន្តអធិដ្ឋានរួមជាមួយគ្នា សូមថែរក្សាអង្គតែមួយនៅក្នុងសេចក្តីស្រឡាញ់ជាមួយបងប្អូនឯទៀតៗ។ ខ្ញុំសូមថ្លែងអំណរគុណដល់ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិកកម្ពុជា (CSC) ដែលចាប់ពីពេលនេះនឹងផ្សាយផ្ទាល់សម្រាប់បងប្អូនតាមហ្វេសបុកនិងយូធូប អំពីអភិបូជាថ្ងៃធម្មតាពេលព្រឹកម៉ោង៦និង៣០នាទី អភិបូជាថ្ងៃអាទិត្យម៉ោង៩ព្រឹក និងអធិដ្ឋានផ្គាំម៉ោង៧ល្ងាច ជារៀងរាល់ថ្ងៃ។ ខ្ញុំសូមអញ្ជើញបងប្អូនទាំងអស់ ចូលមើលតាមហ្វេបុកនិងយូធូបផ្លូវការនេះឲ្យបានច្រើន តែប្រសិនបើយើងគ្មានបងប្អូនអាចចូលរួមដោយអធិដ្ឋានជាអង្គតែមួយជាមួយព្រះគ្រីស្ត ដើម្បីទូលអង្វរព្រះអង្គកែប្រែចិត្តគំនិតរបស់យើងថែមទៀត និងការពារថែរក្សាយើងឲ្យយើងមានសេចក្តីសង្ឃឹមតទៅទៀត។ ឲ្យយើងឯកភាពដើម្បីអធិដ្ឋានថែមទៀត ឲ្យយើងយកចិត្តទុកដាក់ដើម្បីតមអាហារនៅក្នុងរបៀបថ្មី ឲ្យយើងការពារអនាម័យផ្ទាល់ខ្លួន កុំធ្វើដំណើរច្រើន កាត់បន្ថយទំនាក់ទំនងនៅក្នុងសង្គមបណ្តោះអាសន្ន ដើម្បីការពារខ្លួនកុំឲ្យឆ្លងជំងឺដ៏សាហាវនេះ។ យើងតស៊ូដោយសារបិទសាលា យើងតស៊ូដោយសារបិទការជួបជុំតាមបែបសាសនា យើងដឹងថាអ្វីៗទាំងអស់ដែលយើងធ្វើត្រឹមត្រូវថ្ងៃនេះ នឹងមើលឃើញផ្លែនៅពេលក្រោយ។

នៅក្នុងរដូវ៤០ថ្ងៃនេះ ឲ្យយើងបន្តស្រឡាញ់គ្នាទៅវិញទៅមក ដោយបើកត្រចៀក បើកភ្នែកដើម្បីមើលឃើញបងប្អូនជុំវិញយើង ដែលកំពុងមានទុក្ខលំបាក ដែលកំពុងឈឺ ដែលកំពុងឯកោ ដែលកំពុងបាត់បង់សេចក្តីសង្ឃឹម។ យើងបន្តបង្កើនទំនាក់ទំនងជាមួយបងប្អូនជំហានទីពីរជាមួយគ្រីស្តបរិស័ទ តាមរយៈទូរស័ព្ទនិងមធ្យោបាយនានាដែលយើងអាចធ្វើទៅបាន ដើម្បីឲ្យគេយល់ថាសេចក្តីស្រឡាញ់របស់យើងមិនអាចឈប់ដោយសារកូវីដ១៩។ ផ្ទុយទៅវិញ សេចក្តីស្រឡាញ់របស់យើងត្រូវការរីកចម្រើនដើម្បីឈ្នះកូវីដ១៩នេះ ដើម្បីឈ្នះការភ័យខ្លាច ដើម្បីឈ្នះភាពអាត្មានិយមដែលយើងមើលឃើញនៅក្នុងសង្គម។ ព្រះយេស៊ូជាពន្លឺដែលបំភ្លឺពិភពលោកនៅក្នុងពេលវេលាដែលយើងមើលឃើញតែភាពងងឹត សម្រាប់យើងជាគ្រីស្តបរិស័ទឲ្យយើងរកឃើញសេចក្តីសង្ឃឹមរបស់យើង កម្លាំងរបស់យើងនៅក្នុងព្រះយេស៊ូគ្រីស្តផ្ទាល់។ សម្រាប់យើងជាគ្រីស្តបរិស័ទនៅប្រទេសកម្ពុជា ឲ្យយើងនឹកឃើញដល់បុព្វបុរសរបស់យើងក្នុងជំនឿនៅសម័យខ្មែរក្រហម មានលោកអភិបាល លោកបូជាចារ្យ បងប្រុសបងស្រី គ្រីស្តបរិស័ទ ពេលនោះគ្មានឱកាសជួបជុំគ្នា គ្មានឱកាសដើម្បីអធិដ្ឋាន ដើម្បីលើកទឹកចិត្តគ្នាទៅវិញទៅមក និងគ្មានសិទ្ធិថ្វាយអភិបូជា។ ប៉ុន្តែ ពួកគាត់បានតស៊ូរហូតដល់បូជាជីវិតដោយអធិដ្ឋានផ្ទាល់ខ្លួន ដោយដឹងថាទោះបីយើងបាត់បង់អ្វីៗទាំងអស់យើងនៅសល់ព្រះជាម្ចាស់ ដែលប្រទានអំណោយទាន

មួយដែលគ្មានអំណាចណាមួយលើផែនដីនេះអាចបំផ្លាញបានទេ នោះគឺជំនឿ។ ជំនឿរបស់យើង ជាសេចក្តីសង្ឃឹមដែលណែនាំឲ្យយើងតស៊ូតទៅទៀត តាមរយៈមរណសាក្សីយើង តាមរយៈគ្រីស្តបរិស័ទយើងដែលបានតស៊ូយ៉ាងខ្លាំងបំផុសក្នុងសម័យខ្មែរក្រហម យើងដឹងថាយើងបន្តអធិដ្ឋាន យើងបន្តច្រៀងកោតសរសើរព្រះជាម្ចាស់។ ពិតមែន យើងបានចេញពីភាពងងឹតហើយឲ្យយើងរស់នៅធ្វើជាកូននៃពន្លឺ ជំនឿ សេចក្តីសង្ឃឹម ជាពិសេសសេចក្តីស្រឡាញ់ដែលស្ថិតស្ថេរជានិច្ច។

ឱព្រះអម្ចាស់អើយ! សូមបណ្តេញភាពងងឹតពីជីវិតរបស់យើង សូមណែនាំឲ្យពិភពលោកទាំងមូល ឲ្យយើងជាគ្រីស្តបរិស័ទលើផែនដីជាពិសេសនៅប្រទេសកម្ពុជាយើង ឲ្យយើងទទួលព្រះពន្លឺរបស់ព្រះគ្រីស្ត ជាពន្លឺដែលណែនាំឲ្យយើងមើលឃើញជីវិត។ ឱព្រះអម្ចាស់អើយ! សូមបើកភ្នែករបស់យើង សូមបើកដួងចិត្តរបស់យើង ដើម្បីណែនាំឲ្យយើងប្រកាសអស់ពីកម្លាំងកាយកម្លាំងចិត្ត អស់ពីសេចក្តីស្រឡាញ់ ពោរពេញដោយសេចក្តីសង្ឃឹម ពិតមែនខ្ញុំជឿសង្ឃឹមលើព្រះជាម្ចាស់ដែលជាអម្ចាស់នៃជីវិតខ្ញុំ។ អាម៉ែន៕